**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**
លេខ : ០៤៧ ....អ.ជ.ប.ជ.អ

ថ្ងៃ ៣ ៖ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២១

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ÷** របាយការណ៍ចូលរួម កិច្ចប្រជុំជាន់ខ្ពស់ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ឆ្នាំ២០២១។

សេចក្តីដូចមានក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទមានកិត្តិយសដ៏ខ្ពង់ខ្ពស់សូមជម្រាបជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា តាមការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាល ខ្ញុំបាទបានដឹកនាំគណៈប្រតិភូកម្ពុជា ចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ដែលបានប្រព្រឹត្តទៅតាមបណ្តាញវីដេអូ ពីថ្ងៃទី៨ ដល់១០ ខែមិថុនា ឆ្នាំ២០២១កន្លងទៅនេះ។

កិច្ចប្រជុំបានរៀបចំជាពីរផ្នែក ផ្នែកទីមួយ ជាកិច្ចប្រជុំផ្ទាល់ដោយមានការចូលរួមពីអ្នកការទូតតំណាងអចិន្ត្រៃយ៍នៃប្រទេសសមាជិកអង្គការសហប្រជាជាតិ នៅទីស្នាក់ការអង្គការសហប្រជាជាតិ នាក្រុងញូវយ៉ក ។ ផ្នែកទីពីរ នៅក្នុងសម័យប្រជុំពេញអង្គមហាសន្និបាត មានការចាក់ផ្សាយសេចក្តីថ្លែងការណ៍របស់មេដឹកនាំប្រទេសសមាជិកអំពីបញ្ហាអេដស៍ តាមឋានៈចាប់ពីប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ឧបនាយករដ្ឋមន្ត្រី ដល់រដ្ឋមន្ត្រី។ ជាលទ្ធផលនៃកិច្ចប្រជុំ មេដឹកនាំពិភពលោកនៅក្នុងមហាសន្និបាតបានអនុម័តសេចក្តីថ្លែងការណ៍នយោបាយស្តីពីការចាត់វិធានការបន្ទាន់ និងផ្លាស់ប្តូរ ដើម្បីបញ្ឈប់ការរីករាលដាលនៃជំងឺអេដស៍ទូទាំងពិភពលោក នៅឆ្នាំ២០៣០។ ក្នុងនោះ ៖

១) មហាសន្និបាតបានប្តេជ្ញាចិត្ត "ចាត់វិធានការបន្ទាន់ និងធ្វើការផ្លាស់ប្តូរ" ដើម្បីបញ្ចប់វិសមភាពយេនឌ័រ ច្បាប់រឹតត្បិត និងទម្រង់នៃការរើសអើងជាច្រើនដែលបង្កឱ្យមានការរីករាលដាលនៃជំងឺអេដស៍ទូទាំងពិភពលោក ដោយអនុម័តសេចក្តីថ្លែងការណ៍នយោបាយបង្ហាញអំពីវិធានការដើម្បីបញ្ឈប់ជំងឺនេះឱ្យបានត្រឹមឆ្នាំ២០៣០ដូចកាលកំណត់។


អាសយដ្ឋាន : អគារលេខ១៦ ផ្លូវលេខ២៧១ កែង ១៥០ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក ទូរស័ព្ទ (855) 023 882 241 និង ទូរសារ (855) 23 885 129
Tel: (855) 23 882 241 · Fex: (855) 23 885 129 · E-mail: info@naaa.gov.kh · Website: naaa.gov.kh

២) តាមរយៈសេចក្តីថ្លែងការណ៍នយោបាយ មេដឹកនាំពិភពលោកបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តអន្តរជាតិដើម្បីសម្រេចគោលដៅនេះ។ មេដឹកនាំពិភពលោកបានប្រកាសថា "ចុងបញ្ចប់នៃជំងឺអេដស៍គឺអាចឈានដល់គោលដៅ ប៉ុន្តែចាំបាច់ត្រូវធ្វើសកម្មភាពជាបន្ទាន់"។ មេដឹកនាំទាំងឡាយបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងអំពីការរីករាលដាលនៃជំងឺអេដស៍ដែលនៅតែជាភាពអាសន្នសម្រាប់ពិភពលោកហើយបានប្តេជ្ញាកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មីឱ្យនៅក្រោម ៣៧០.០០០ករណី ក្នុងមួយឆ្នាំ និងការស្លាប់ដែលទាក់ទងនឹងជំងឺអេដស៍ប្រចាំឆ្នាំមកនៅក្រោម ២៥០.០០០នាក់ នៅត្រឹមឆ្នាំ២០២៥។ មេដឹកនាំទាំងអស់បានសន្យាថានឹងបញ្ចប់វិសមភាពដែលអ្នកផ្ទុកមេរោគអេដស៍ត្រូវប្រឈម និងពង្រឹងការឆ្លើយតបមេរោគអេដស៍ តាមរយៈការបង្កើនការចូលរួមជាមួយអ្នកពាក់ព័ន្ធជាច្រើន។

៣) សហពន្ធ័រុស្ស៊ីបានលើកសំណើធ្វើវិសោធនកម្មមួយចំនួនពាក់ព័ន្ធនឹង ការកាត់បន្ថយគ្រោះថ្នាក់ ការដាក់ទោសទណ្ឌដល់អ្នកប្រើប្រាស់គ្រឿងញៀន ស្ត្រីពេស្យា ជាដើម។ តាមរយៈការបោះឆ្នោត សំណើវិសោធនកម្មរបស់សហព័ន្ធរុស្ស៊ីមិនទទួលបានជោគជ័យទេ ដោយសមាជិកភាគច្រើនមិនគាំទ្រ (ជាលទ្ធផលនៃការបោះឆ្នោតលើសំណើធ្វើវិសោធនកម្ម ៖ ក) ការស្នើសុំលុបកថាខណ្ឌ 1(C), 28, 37, 65(a) និង65(b) សម្លេងប្រឆាំងមាន១១៦ សម្លេងគាំទ្រមាន១៣ សម្លេងអនុបវាទមាន១៩ ខ) ការលុបកំណត់ចំណាំនៅខាងក្រោមទំព័រលេខ១៥ និងកថាខណ្ឌប្រតិបត្តិការ 60(a) សម្លេងប្រឆាំងមាន១១៧ សម្លេងគាំទ្រមាន៣ សម្លេងអនុបវាទមាន២៨ គ) ការលុបពាក្យ "ផ្អែកលើសិទ្ធិ" ក្នុងកថាខណ្ឌប្រតិបត្តិការ 70 និងការលុបកថាខណ្ឌប្រតិបត្តិការ 70(c) សម្លេងប្រឆាំងមាន១១៩ សម្លេងគាំទ្រមាន៥ សម្លេងអនុបវាទមាន២៤)។ អត្ថបទនៃ"សេចក្តីថ្លែងការណ៍នយោបាយស្តីពីមេរោគអេដស៍និងជំងឺអេដស៍ ៖ ការបញ្ចប់វិសមភាព និងការឈានទៅរកការបញ្ចប់ជំងឺអេដស៍ត្រឹមឆ្នាំ២០៣០" (ឯកសារ A/75/L.95) ត្រូវបានអនុម័តដោយសម្លេងគាំទ្រចំនួន១៦៥ សម្លេងមិនគាំទ្រចំនួន៤ (បេឡារុស នីការ៉ាហ្កា សហព័ន្ធរុស្ស៊ី និងស៊ីរី) និងដោយគ្មានសម្លេងអនុបវាទ។

៤) អំពីសេចក្តីថ្លែងការណ៍របស់ប្រទេសកម្ពុជា ៖ ខ្ញុំបាទបានលើកឡើងថា ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោម ៧ប្រទេស ដែលបានសម្រេចចនូវ គោលដៅ៩០-៩០-៩០ ក្នុងឆ្នាំ២០១៧ ដោយសារការអនុវត្តភាពជាដៃគូរវាងស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងប្រជាជនងាយរងគ្រោះ។ ទោះយ៉ាងណាក្តី ប្រទេសកម្ពុជាមិនប្រាកដជាអាចកាត់បន្ថយការឆ្លងថ្មីរហូតដល់គោលដៅឆ្នាំ២០២៥នោះទេ ដោយសារកង្វះថវិកាសម្រាប់កម្មវិធីបង្ការមេរោគអេដស៍ និងដោយសារផលប៉ះពាល់ពីការរីករាលដាលនៃមេរោគកូវីដ-១៩ ដែលនាំឱ្យមានការកាត់បន្ថយការវិនិយោគក្នុងវិស័យសុខភាពសាធារណៈ។ ប្រទេសកម្ពុជាប្តេជ្ញាអនុវត្តអភិក្រមយកប្រជាជនជាគោល និងអភិក្រមសមាហរណកម្ម តាមរយៈកំណែទម្រង់ និងគោលនយោបាយផ្តល់សេវាសុខភាពសកល និងការគាំពារសង្គម។ ខ្ញុំបាទបានគូសបញ្ជាក់ថា ក្នុងរយៈពេល៥ឆ្នាំខាងមុខ ប្រទេសកម្ពុជានឹងសម្របសម្រួលការអនុវត្តការឆ្លើយតបនឹងមេរោគអេដស៍ទូទាំងប្រទេស ដោយការទទួល

ខុសត្រូវរួមគ្នា ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍នយោបាយនៃមហាសន្និបាតអង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍នេះ។

សេចក្តីដូចជម្រាបជូនខាងលើ សូម **សម្តេចតេជោ** មេត្តាជ្រាបជាបរាយការណ៍ដ៏ខ្ពង់ខ្ពស់។

សូម **សម្តេចតេជោ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំបាទ។

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង-មូលី**

**ចម្លងជូន÷**

-ព្រឹទ្ធសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងសុខាភិបាល

-ឯកសារ កាលប្បវត្តិ